**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

# យុទ្ធនាការយល់ដឹងអំពីជំងឺមហារីកសុដន់ Fit For Hope ឆ្នាំ 2021 របស់ អេ អាយ អេ ខេមបូឌា បានបញ្ចប់ជាមួយការគាំទ្រផ្នែកសីលធម៌ និងហិរញ្ញវត្ថុ

**ភ្នំពេញ ថ្ងៃទី 14 ខែកុម្ភៈ ឆ្នាំ 2022** – ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក (អេ អាយ អាយ ខេមបូឌា) បានបិទបញ្ចប់ជាផ្លូវការនូវយុទ្ធនាការយល់ដឹងអំពីជំងឺមហារីកសុដន់ Fit for Hope ឆ្នាំ 2021 ជាមួយនឹងការប្រគល់ប្រាក់ចំនួន 40,557 ដុល្លារអាមេរិក ដល់មន្ទីរពេទ្យព្រះសីហនុមណ្ឌលក្តីនៃសង្ឃឹម (SHCH)។

ទឹកប្រាក់ទទួលបាននេះនឹងផ្តល់ជូនមន្ទីរពេទ្យក្នុងការជួយពិនិត្យរោគវិនិច្ឆ័យលើជំងឺមហារីកសុដន់ដល់អ្នកជំងឺបានជិត 2,605ករណី ព្យាបាលអ្នកជំងឺបានជាង 2,210 ករណី និងបោះពុម្ពខិត្តប័ណ្ណប្រហែល 83,300 ច្បាប់ ដើម្បីបង្កើនការយល់ដឹងអំពីជំងឺមហារីកសុដន់។ Fit for Hope ដែលធ្វើឡើងចាប់ពីខែតុលាដល់ចុងខែធ្នូកាលពីឆ្នាំមុន ទទួលបានការបរិច្ចាគពីសាធារណៈជនក៏ដូចជា ធនាគារកម្ពុជាសាធារណៈ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ពីអតិថិជន ទីប្រឹក្សាផែនការជីវិត និងបុគ្គលិករបស់អេ អាយ អេ ខេមបូឌា ។

អេ អាយ អេ ខេមបូឌា ដែលជាអ្នកដឹកនាំឈានមុខគេក្នុងការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏បានចូលរួមចំណែក 5% នៃបុព្វលាភធានារ៉ាប់រងដែលប្រមូលបានពីបណ្ណសន្យារ៉ាប់រងដែអតិថិជនបានទិញ ជាមួយនឹងការផ្តល់ជូនលើការធានារ៉ាប់រងជំងឺមហារីកក្នុងអំឡុងពេលយុទ្ធនាការនេះ។ យុទ្ធនាការនេះត្រូវបានអនុវត្តជាកាយវិការសុច្ឆន្ទៈជំនួសអតិថិជនរបស់ អេ អាយ អេ ចូលរួមជួយត្រលប់ដល់សង្គមវិញ។

លោក យ៉ាន សាឌីន នាយកប្រតិបត្តិនៃមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម បានទទួលមូលប្បទានប័ត្រទឹកប្រាក់ពីលោក Andrew Loh អគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ ខេមបូឌា ក្នុងពិធីនេះផងដែរ។លោក Ong Ming Teck អគ្គនាយកប្រតិបត្តិនៃធនាគារកម្ពុជាសាធារណៈ និង លោក Alan Wee នាយកអង្គភាពពាណិជ្ជកម្មនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ក៏ដូចជាទីប្រឹក្សាផែនការជីវិត និងបុគ្គលិករបស់អេ អាយ អេក៏បានចូលរួមផងដែរ។

លោក Andrew Loh មានប្រសាសន៍ថា៖ “យើងសូមអរគុណដល់សប្បុរសជនគ្រប់រូប ដូចជា ធនាគារកម្ពុជាសាធារណៈ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ដែលបានបរិច្ចាគ និងជួយដល់សុខុមាលភាពរបស់អ្នកជំងឺមហារីកសុដន់រាប់រយនាក់នៅទូទាំងប្រទេស។ វាពិតជាគួរឱ្យរីករាយណាស់ដែលប្រជាជនកម្ពុជាជាច្រើនមកពីគ្រប់មជ្ឈដ្ឋានបានមកជួបជុំគ្នាដើម្បីគាំទ្រយុទ្ធនាការរបស់យើង បើទោះបីជាស្ថានភាពសេដ្ឋកិច្ច និងសង្គមដែលបណ្តាលមកពីជំងឺរាតត្បាតកាលពីឆ្នាំមុនក៏ដោយ។

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

"ជាពិសេសសូមអរគុណមន្ទីរពេទ្យព្រះសីហនុមជ្ឈមណ្ឌលនៃក្តីសង្ឃឹម ដែលសហការណ៍ជាមួយយើង។ វាជាកិត្តិយសមួយក្នុងការចាប់ដៃគូជាមួយមន្ទីរពេទ្យដែលសម្រេចបានច្រើនក្នុងការលើកកំពស់ការយល់ដឹងពីផលប៉ះពាល់នៃជំងឺមហារីកសុដន់ និងផ្តល់ជំនួយផ្នែកវេជ្ជសាស្រ្ត និងហិរញ្ញវត្ថុតាមរយៈការពិនិត្យដោយឥតគិតថ្លៃប្រកបដោយគុណភាពខ្ពស់លើការវិភាគរោគវិនិច្ឆ័យ ការផ្តល់ការប្រឹក្សា និងការព្យាបាល។

"អេ អាយ អេ ខេមបូឌា ជឿជាក់ថា ការបង្កើនការយល់ដឹងអំពីហានិភ័យ និងរោគសញ្ញាដំបូងនៃជំងឺមហារីកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយអត្រាមរណភាព ហើយយើងសង្ឃឹមថាស្រ្តីយល់អំពីកត្តាទាំងនេះ ចាត់វិធានការបង្ការចាំបាច់ និងប្រើប្រាស់សេវាកម្មរបស់មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ឱ្យបានពេញលេញ។"

លោក យ៉ាន សាឌីន បានមានប្រសាសន៍ថា៖ "ការខិតខំប្រឹងប្រែងរបស់ អេ អាយ អេ ខេមបូឌា ក្នុងការគាំទ្រមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម នឹងសង្ឃឹមថានឹងមានស្រ្តីកាន់តែច្រើនឡើងៗដែលបានទទួលការពិនិត្យ។ ប្រជាជនកម្ពុជាជាច្រើនពន្យារពេលមកទទួលយកការពិនិត្យព្យាបាល ដោយសារហេតុផលជាច្រើន ហើយយើងសង្ឃឹមថាបេសកកម្មរបស់ Fit for Hope ដើម្បីបង្កើនការយល់ដឹងជាសាធារណ: និងចែករំលែកព័ត៌មាននឹងលើកទឹកចិត្តពួកទទួលយកការពិនិត្យរោគវិនិច្ឆ័យតាំងពីដំណាក់កាលដំបូងដើម្បីកាត់បន្ថយអត្រាកើតជំងឺមហារីកសុដន់ និងបង្កើនអត្រាជោគជ័យនៃការព្យាបាល។

Fit for Hope ដែលប្រារព្ធឡើងជារៀងរាល់ឆ្នាំដោយភ្ជាប់ជាមួយនឹងខែនៃការយល់ដឹងអំពីជំងឺមហារីកសុដន់ត្រូវបានរៀបចំជាលើកដំបូងជាមួយមន្ទីរពេទ្យមិនរកប្រាក់ចំណេញក្នុងឆ្នាំ 2017។ មន្ទីរពេទ្យព្រះសីហនុមជ្ឈមណ្ឌលក្តីសង្ឃឹម ដែលបានចាប់ផ្តើមប្រតិបត្តិការនៅឆ្នាំ 1996 ដំណើរការកម្មវិធីជំងឺមហារីកសុដន់ដែលដំណើរការយូរជាងគេបំផុតរបស់ប្រទេស ហើយផ្តល់ជូននូវការពិនិត្យដោយឥតគិតថ្លៃ និងការធ្វើរោគវិនិច្ឆ័យផ្សេងទៀត និងនីតិវិធីព្យាបាលសម្រាប់អ្នកដែលមិនមានលទ្ធភាព។

យុទ្ធនាការ Fit For Hope ឆ្នាំ 2021 ក៏បានជួយស្រ្តីជាង 617 នាក់ទទួលយកការផ្តល់ជូនរបស់ អេ អាយ អេ ខេមបូឌា លើការពិនិត្យមហារីកសុដន់ដោយឥតគិតថ្លៃ ជួយដល់ស្រ្តីក្នុងការស្វែងយល់អំពីជំងឺនេះ និងរបៀបពិនិត្យរោគវិនិច្ឆ័យរកឃើញទាន់ពេលវេលា ងាយស្រួលក្នុងការព្យាបាល ផ្តល់ឱកាសខ្ពស់ក្នុងការជាសះស្បើយ និងសង្គ្រោះជីវិត។ ការស្វែងយល់អំពីជំងឺនេះធ្វើឲ្យពួកគាត់យកចិត្តទុកដាក់បន្ថែមទៀតលើរាងកាយរបស់ពួកគាត់ ហើយយកបញ្ហាទៅក្នុងដៃរបស់ពួកគេដោយធ្វើការពិនិត្យដោយខ្លួនឯង ទទួលបានព័ត៌មាន និងទៅពិគ្រោះជាមួយវេជ្ជបណ្ឌិតជំនាញរាល់សំណួរ ឬចម្ងល់ណាមួយ។

ក្នុងឆ្នាំ 2020 ទីភ្នាក់ងារអន្តរជាតិសម្រាប់ការស្រាវជ្រាវលើជំងឺមហារីកបានបង្ហាញថា ជំងឺមហារីកសុដន់ជាជំងឺមហារីកដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញញឹកញាប់បំផុតលើពិភពលោក។ សព្វថ្ងៃនេះជំងឺមហារីកសុដន់ជា

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

មូលហេតុប្រឈមខ្លាំងនៃការស្លាប់ដោយសារជំងឺមហារីកចំពោះស្រ្តី និងឈរលំដាប់ទី 5 នៃការស្លាប់ដោយសារជំងឺមហារីកទាំងអស់។

សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបដែលដំណោះស្រាយជីវិត និងជំងឺធ្ងន់ធ្ងររបស់ AIA អាចការពារគ្រួសារអ្នក និងខ្លួនអ្នកបាន សូមទាក់ទង សេវាកម្មអតិថិជនរបស់ អេ អាយ អេ តាមរយៈលេខទូរស័ព្ទ 086 999 242 ឬចូលទៅកាន់គេហទំព័រ aia.com.kh ។

***អំពី អេ អាយ អេ***

*អេ អាយ អេ គ្រុប លីមីតធីត និង សាខា (តទៅហៅថា អេ អាយ អេ “AIA” ឬ គ្រុប “Group”) មានក្រុមហ៊ុនធានារ៉ាប់រងជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង និង ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅទីក្រុងហុងកុង SAR ប្រទេសថៃ សឹង្ហបូរី ម៉ាឡេស៊ី ចិនដីគោក កូរ៉េខាងត្បូង ហ្វីលីពីន អូស្ត្រាលី ឥណ្ឌូនេស៊ី (ចិន) តៃវ៉ាន់ វៀតណាម ញូហ្ស៊ីលែន ម៉ាកាវ SAR ប្រ៊ុយណេ កម្ពុជា មីយ៉ាន់ម៉ា ក្រុមហ៊ុនបុត្រសម្ព័ន្ធដែល ៩៩ ភាគរយនៅប្រទេសស្រីលង្កា និង ក្រុមហ៊ុនបណ្តាក់ទុនរួម ៤៩ ភាគរយនៅប្រទេសឥណ្ឌា។*

*ក្នុងពេលបច្ចុប្បន្ន អាជីវកម្មរបស់ក្រុមហ៊ុន គឺដូចគ្នានិង អេអាយអេ ដែលត្រូវបានបង្កើតឡើងលើកដំបូងនៅទីក្រុងសៀងហៃកាលពីមួយសតវត្សកន្លងទៅក្នុងឆ្នាំ ១៩១៩ ។ ជាក្រុមហ៊ុនឈានមុខគេមួយនៅលើទីផ្សារ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (អតីត-ជប៉ុន) ដោយផ្តោតទៅលើបុព្វលាភធានារ៉ាប់រងជីវិត និង មានតួនាទីនាំមុខគេនៅគ្រប់ទីផ្សារភាគច្រើនរបស់ខ្លួន ។ ក្រុមហ៊ុនមានទ្រព្យសម្បត្តិសរុបចំនួន ៣២៦ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។*

*អេ អាយ អេ ឆ្លើយតបតាមតម្រូវការនៃប្រាក់សន្សំ និង ការការពាររយៈពេលវែងរបស់ ពលរដ្ឋទូទៅតាមរយៈការផ្តល់នូវផលិតផលដ៏សម្បូរបែប និង សេវាកម្មជាច្រើនរួមមាន ការធានារ៉ាប់រងជីវិត គ្រោះថ្នាក់ ការធានារ៉ាប់រងសុខភាព និង ផែនការសន្សំប្រាក់ ។ ក្រុមហ៊ុនគ្រុប ក៏ផ្តល់ផងដែរនូវប្រាក់អត្ថប្រយោជន៍សម្រាប់បុគ្គលិក ផ្តល់ឥណទានអាយុជីវិត និង សេវាកម្មប្រាក់សោធននិវត្តន៍ ។ តាមរយៈបណ្តាញភ្នាក់ងារ ដៃគូ និង បុគ្គលិកដ៏ទូលំទូលាយនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក អេអាយអេ បានផ្តល់ដល់ម្ចាស់ប័ណ្ណធានានូវ ប័ណ្ណធានារ៉ាប់រងរូបវន្តបុគ្គលច្រើនជាង ៣៨ លាននាក់ និង សមាជិកដែលបានចូលរួម ផែនការធានារ៉ាប់រងជាក្រុមជាង ១៦ លាននាក់។*

*អេ អាយ អេ គ្រុបលីមីតធិត (AIA Group Limited) ត្រូវបានដាក់បញ្ចូលក្នុង តារាងនៃក្រុមប្រឹក្សាភិបាលចម្បងនៃ គណកម្មាធិការផ្សារមូលបត្រទីក្រុងហុងកុង (Main Board of The Stock Exchange of Hong Kong Limited) ដែលស្ថិតក្រោមច្បាប់ផ្សារមូលបត្រ “១២៩៩” ស្របតាមច្បាប់ស្តីពី ការទទួលប្រាក់តម្កល់នៃសហរដ្ឋអាមេរិក (កម្រិត ១) A (American Depositary Receipts (Level 1) ដែលធ្វើពាណិជ្ជកម្មលើទីផ្សារស្របច្បាប់ (រូបសញ្ញា: “AAGIY”)។*

---

**ទំនាក់ទំនងសារព័ត៌មាន**
**ម៉េង ដាណែត**
ប្រធានផ្នែកទីផ្សារជាន់ខ្ពស់
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
Daneth-d.Meng@aia.com